ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្តីពី
## ប្រព័ន្ធការមេរ៉ាត្រួតពិនិត្យគយ

---

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដាក់ឱ្យអនុវត្តប្រព័ន្ធការមេរ៉ាត្រួតពិនិត្យគយ ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង ត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូនដោយអនុលោមតាមច្បាប់ស្តីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់នូវកិច្ចប្រតិបត្តិការប្រព័ន្ធការមេរ៉ាសម្រាប់ឃ្លាំត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូន នៅតាមបណ្តាការិយាល័យគយនិងរដ្ឋាករថ្នាក់មូលដ្ឋាន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

និងបញ្ជូនព័ត៌មានមកថ្នាក់កណ្ដាល ជាជំនួយក្នុងការផ្ទៀងផ្ទាត់ព័ត៌មានទំនិញ និងមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែន ជាមួយនឹងព័ត៌មានទទួលបានពីប្រព័ន្ធគ្រប់គ្រងហានិភ័យគយ ប្រព័ន្ធព័ត៌មានសម្ងាត់គយ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធពាក់ព័ន្ធផ្សេងទៀត សំដៅជំរុញបន្ថែមនូវកិច្ចសម្រួលពាណិជ្ជកម្ម និងពង្រឹងអនុលោមភាពតាមច្បាប់ស្ដីពីគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពតម្លើងនិងដាក់ឱ្យអនុវត្តប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយនៅតាមបណ្ដាការិយាល័យបំពេញបែបបទបញ្ចេញទំនិញពីគយ ដោយតភ្ជាប់មកប្រព័ន្ធមេ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាដំណាក់ៗ តាមលទ្ធភាពធនធានហិរញ្ញវត្ថុ និងតាមតម្រូវការជាក់ស្ដែង។

**ប្រការ ៤.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានភារកិច្ច÷

- រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ
- បង្កើតអង្គភាពគ្រប់គ្រងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ ដើម្បីសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោង និងកិច្ចដំណើរការប្រព័ន្ធ
- រៀបចំយន្តការគ្រប់គ្រង និងកសាងសេចក្ដីណែនាំចាំបាច់នានាស្ដីពីនីតិវិធី សំដៅធានាឱ្យមានតម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ
- រៀបចំផែនការសកម្មភាពកិច្ចប្រតិបត្តិការ ថែទាំ ជួសជុល និងកែលម្អប្រព័ន្ធ។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៧

អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ